ឧប សៅ សង្ហា

ហាត៌ នៃ កំណែទំរង់ សីលធម៌

មាតិកា

សេចក្តីផ្តើម 1
ក្រមសីលធម៌ បុគ្គល 4
ក្រមសីលធម៌ ប្រជាពលរដ្ឋ 6
ក្រមសីលធម៌ នៃ ជាតិមនុស្ស 7
សេចក្តីសន្និដ្ឋាន 7

សេចក្តីផ្តើម

នៅក្នុង សាសនា សកល ធំៗ និង មនុស្សជាតិ បរិស័ទ សុទ្ធ តែ មាន គោលការណ៍ នៃ សីលធម៌ ដូចគ្នា។ ប៉ុន្តែ នៅក្នុង ទិដ្ឋិ នៃ សាសនា ដែល អះអាង ថា ផ្តល់ នូវ សេចក្តីស្នេហា ចំពោះ មនុស្សលោក ក៏ នៅ តែ មាន មនុស្ស ក្បាច្បាល ទោស: រវាង គ្នា និង គ្នា, ហើយ សាសនា នៃ ពិសម័យ[1] នេះ ក៏ អាច មាន លទ្ធ

[1] ពិសម័យ : សេចក្តីស្រឡាញ់។

ភាព បង្កើត នូវ ភាពអាក្រក់ បំផុត ផង ដែរ ដូចជា បង្ខំ មនុស្ស អោយ ជឿ ឬ ផ្លាស់ សាសនា ដោយ ប្រើ វិធី ហិង្សា ដូច យ៉ាង សង្គ្រាម សាសនា ជា អាទិ។ រីឯ មនុស្សជាតិ បរិស័ទ វិញ ដែល ពុំមាន ប្រភាព ទៅលើ មនុស្សលោក ដូច អំណាច សាសនា ហើយ សកលនិយម សីលធម៌ ឬ សីលធម៌ លោកិយ (morale séculaire) របស់ ខ្លួន ក៏ នៅ មាន កង្វះ និង ភាព ខ្វាក់ ជ្រើនណាស់ ដូច្នេះ សីលធម៌ នេះ ក៏ មិន បាន ប្រកាស ថា ខ្លួន មាន វិសិដ្ឋភាព លើ សីលធម៌ សាសនា នោះដែរ។

ដូច្នេះ វា ហាក់ដូចជា សីលធម៌ ទាំង ខាង សាសនា និង សីលធ ម៌ លោកិយ វា សម នឹងយកមក ពិចារណា ឡើងវិញ នៅក្នុង សេចក្ដីសង្ឃឹម ថា វា នឹងអាច ធ្វើ កំណែទំរង់ តាម វិធីសាស្ត្រ ថ្មី ណាមួយ នៅក្នុង ជម្រៅ ទឹកចិត្ត របស់ មនុស្ស ដែល រស់នៅ នៅក្នុង សង្គម មិស្សភាគ (société complexe) ដែល ជា សង្គម មាន ការរីកចំរើន ក្នុង ផ្នែក សម្ភារ:, វិទ្យាសាស្ត្រ តែ នៅក្នុង ផ្នែក សីលធម៌ វាហាក់បីដូចជា មាន ធ្ងរលុង ព្រោះ ភាពទំនើប វា លាក់ជ្រាំង សេចក្ដីគ្មានរំពឹង របស់ បុគ្គល នៅក្នុង សង្គម។

បើសិន ជា យើង អោយ និយមន័យ នៃ សញ្ញាណ នៃ មនុស្ស តាម ការអះអាង ដោយ ខ្លួនឯង ដ៏ ស្វយ័ត[2] នៃ ពាក្យ « ខ្ញុំ » ដែល វា ស្ថិតនៅ ដោយ ប្រការ ដាច់ខាត ក្នុង ខ្លឹមសារ របស់ វា (គឺថា គ្មាន នរណា ម្នាក់ អាច និយាយ ថា ខ្ញុំ ជំនួស ខ្ញុំ បាន

[2] ការអះអាង ដោយ ខ្លួនឯង ដ៏ ស្វយ័ត : auto affirmation égocentrique.

ទ្បើយ), ដែលហ្នឹង វា មាន នយ ថា ការ: មនុស្ស មាន គោលការ ណ៍ ស្វយ័ត ដែល ផ្ត ល់ នូ វ អាទិភាព និង អោយ តម្លៃ ទៅ លើ ខ្លួនឯង ជាង អ្នកដទៃ។ ប៉ុន្តែ ក្នុង ពេ ល តែ មួ យ នោ ះ ដែ រ មនុ ស្ស ទាំ ង ទ្ប ាយ រ ដែ ង មាន គោ ល ការ ណ៍ រ ាប់ ប ញ្ជូ ល ស ញ្ញ ា ណ នៃ « យើ ង » ទ ៅ ក្ន ុ ង ចិ ត្ត ខ្ល ួ ន ឯ ង ផ ្ទ ា ល់ ដ ែ ល ត ឿ ន ខ្ល ួ ន ឯ ង ឆ្ពោ ះ ទ ៅ រ ក ការ ទ ំ ន ា ក ់ ទ ំ ន ង ស ហ គ ម ន ៍ និ ង រ ាប ់ អ ា ន អ្ន ក ដ ទ ៃ ជ ាម ួ យ នឹ ង គ ោ ល ក ំ ន ិ ត « ร ป ส ់ យ ើ ง » (ក្ន ួ ส ារ, ម ិ ត ្ត ภ ก ្ ถ ิ , ม า ต ุ ภ ู ม ิ) ห ื ย ก ร ว ด ื ง ถ า ต ั ง ต ี ก ำ ณ ื ต ม ก ม ห ุ ส ว ล ก ม ี ส ช ก ่ ต ร ว ก า ร ป ร ต ิ ต ั ท ธ ช า ช ั ท ช ั ม ว ย ก ู ง ด ั ว ป ร ะ ห ุ ส ว ล ก ม ี ช า ธ ม ว ช า ต ิ ส า ร ช า ต ิ ข อ ง ก า ร ส ว ง ร ก ท ั ก ท ั ง ช า ม ว ย อ ก ด ท ว ย ด ล ช ม ล ฐ า ง ก ร ี ะ ข อ ง ก ำ ณ ื ต ข อ ง น ร ะ ส ง ค ม ห ค ล ก า ร ณ ์ ข อ ง ส ม า ห ร ณ ก ม ม « ร ป ส ่ ย ื ง » น ะ ห ื ย ด ว ล น ำ ห ว ย ม ห ุ ส ว อ ช ธ ว ี ท ล ิ ก ม ม ด ล ่ ช ว ิ ต ส ำ ร ป ่ « ย ื ง » ห ม ห ุ ส ว ล ก ม ี ช ร ิ ต ล ก ข ณ ะ ท ว ก ม ว ว ิ ธ ี (double logiciel) : ទ ី ១ ជ ំ ร ุ ญ ទ ៅ ร ก ม ជ ្ ฌ ต ្ ต ข ิ ย ม[3] ដ ោ យ ច ង ់ អ ោ យ អ ្ ន ก ដ ទ ៃ ធ ្ ว ើ ព ល ิ ก ม ្ ม ส ำ ร ป ់ ข ្ ล ួ น , ទ ី ២ ជ ំ ร ุ ญ ទ ៅ ร ก ป ร ท ต ្ ต ภ า ព[4], ม ิ ต ្ ต ภ า ព ន ិ ง ส ច ก ្ ต ี ส ្ ห ว ห ា ។ ต ែ ห ว ร ิ ย ช ม ์ ข อ ง ม ห ุ ส ว ช ว ต ิ ม ว ย ข ิ ท ธ ิ ก ว ร ท ว ก ม ช ্ ฌ ต ্ ต ข ิ ย ม ช ร ะ ห ว ร ร ส ่ ห ว ห ว ข ว ง ช ม ว ช า ต ิ ก ্ ต ี ส ง ค ม ก ্ ต ี ต ร ู ว ร อ ห ย ม ว ก ร ป ร ก ว ต ป ร ด ง ง ។ ต ែ ទ ោ ះ ป ី យ ៉ ា ง ណ ា ห ើ យ ช ว ก า ร ต ิ ท ។

[3] មជ្ឈត្តនិយម : égocentrisme. ដែល គិត តែ ខ្លួនឯង ជា ផ្តើម ក្នុងលោក។
[4] ปรทัตภาพ : altruisme. ภาพ នៃ អ្នក ដែ ล ย ើ ญ ป ร ย ោ ช ន ์ អ ្ ห ก ด ท ว ។

កម្មវិធី នៃ បរទេសភាព និង សាមគ្គីភាព វា ស្ថិត នៅ ក្រៅ ទីកន្លែង ក្នុង សង្គម តែ ជា រឿយៗ វា ស្ថិត នៅក្នុង តែ ចិត្ត ឬ សម្រាន្តលក់ តែម្តង។ ប៉ុន្តែ វា ក៏ អាច ភ្ជាក់ឡើង ដែរ, ដូច្នេះ កម្មវិធី ទី២ នេះឯង ដែល ត្រូវ បណ្តុះបណ្តាល អោយ វា កំរើក និង កើនឡើង តាម កំណែទំរង់ នៃ សីលធម៌ ក្នុង ទិសភាគ ដូច ខាង ក្រោម នេះ :

ក្រមសីលធម៌[5] បុគ្គល

ក្រមសីលធម៌ នេះ ត្រូវចាំបាច់ ធ្វើ សមាហរណកម្ម នៃ គោលការណ៍ ស្វ័យពិនិត្យ ជា អចិន្ត្រៃយ៍ ទៅក្នុង សតិសម្បជញ្ញៈ និង ចរិយា របស់ បុគ្គល ម្នាក់ៗ ដ្បិត ដោយ មិនដឹងខ្លួន មនុស្ស យើង ចេះតែ បញ្ជោត ឥតឈប់ឈរ និង ភ្ញកកុហក ខ្លួនឯង ជា និច្ច។ យើង ច្រើន តែ នឹកឃើញ ដល់ អ្វី ដែល មាន ប្រយោជន៏ ដល់ ខ្លួនឯង, ហើយ ការមើលឃើញ មកលើ ខ្លួនឯង និង ទៅលើ អ្នកដទៃ ច្រើន តែ ជា មជ្ឈត្តនិយម។ ដូច្នេះ បើសិន ជា ចង់ ធ្វើ កំណែទំរង់ ក្រមសីលធម៌ យើង មិន អាច សន្សំសំចៃ ស្វ័យពិនិត្យ និង ការរិះគន់ បានឡើយ។ ម្យ៉ាងទៀត យើង មិន ត្រូវ មាន ជំនឿ ថា ដំណោះស្រាយ នៃ អកុសល ផ្លូវចិត្ត និង សីលធម៌ របស់ យើង វា ស្ថិត ទាំងស្រុង នៅលើ ដៃ អ្នកដទៃ, អ្នកចិត្តតិកិច្ចា (psychothérapeute) ឬ អ្នកចិត្តវិភាគ (psychanalyste)។ ជា ការពិតហើយ ជំនួយ របស់ អ្នកដទៃ ត្រូវ

[5] ក្រមសីលធម៌ : éthique.

មាន ជា ចាំបាច់ សំរាប់ យើង ដើម្បី អោយ យើង អាច ស្គាល់ ខ្លួនឯង, តែ បើ ក្ខាន ស្វ័យពិនិត្យ ក៏ យើង មិនអាច ធ្វើ សមាហរណកម្ម នៃ ការមើលឃើញ របស់ អ្នកដទៃ មក លើ យើង ក្នុង គោលដៅ នៃ ការប្រឹងប្រែង ជា រៀងរហូត ដើម្បី ស្គាល់ ខ្លួនឯង អោយ កាត់ តែ ប្រសើរឡើង ជាមួយនឹង គុណវិបត្ត របស់ យើង ត្រប់ បែបយ៉ាង ដែល អ្នកដទៃ គេ មើលឃើញ។

គួរ កត់សម្គាល់ ថា យើង បាន បង្ហាញ នូវ ការយល់ដឹង ពេញ លេញ របស់ យើង ពី អ្នកដទៃ នៅក្នុង ពិភព ស្រមើលស្រមៃ និង សោភ័ណភាព នៃ ប្រលោមលោក, ល្ខោន, កុន។ ដូចយ៉ាង យើង អាច មាន លទ្ធភាព យល់ដឹង អំពី តួល្ខោន ដែល ស្ថិត នៅ ឆ្ងាយណាស់ ពី យើង ដែល រស់នៅ ក្នុង ពិភព កម្រមាន, ឬ ជា មនុស្សលោក មិនច្បាស់, ជួនកាល ជា មនុស្ស ឧក្រិដ្ឋ សម្លាប់ មនុស្សពាល ដើម្បី សងសឹក ព្រោះ នរ:នោះ បាន ធ្វើ ឃាត ឱពុក របស់ ខ្លួន, ក្នុង ករណី នេះ យើង ច្បាស់ ជា យល់ ដឹង ថា អំពើ នោះ វា មាន ភាពយុត្តិធម៌ របស់ វា, ជួនកាល ជា អ្នករងគ្រោះ និង ជា ជនអនាថា ដេក តាម ចិញ្ចើមផ្លូវ ដែល នាំ អោយ យើង មាន ចិត្ត អាណិត។ តែ នៅពេល ដែល យើង មើល កុន ល្ខោន អាន ប្រលោមលោក ចប់ កាលណា ហើយ រីល ត្រឡប់ មក រស់នៅ ក្នុង ជីវិត រៀងរាល់ ថ្ងៃ របស់យើង វិញ យើង បាត់ ភ្លាម សមត្ថភាព អាច យល់ដឹង អ្នកដទៃ ដែល រស់ នៅ ក្បែរ យើង ដូចយ៉ាង បើ យើញ ឃាតករ ឬ ជនអនាថា ដូច នៅក្នុង រឿងប្រឌិត គឺ ច្បាស់ ជា យើង គិត ក្នុង ចិត្ត ភ្លាម ថា

នរ:នោះ ជា ជនពាល ឬ ឥរិយាបថ។ ផ្ទុយទៅវិញ គួរ តែ យើង បន្ត ចែករំលែក ភាពជាក់ស្តែង ប្រចាំថ្ងៃ នៃ ការយល់ដឹង ដែល យើង ជួបប្រទះ នៅក្នុង ជីវិត ពិត ដូចគ្នានឹង រឿងប្រឌិត ក្នុង រឿងកុន ល្ខោន ប្រលោមលោក។

ដូច្នេះ កំណែទំរង់ ក្រមសីលធម៌ ត្រូវ បណ្តុះបណ្តាល ដោយ អាទិ ភាព ស្វ័យពិនិត្យ និង សម្បទា នៃ ការយល់ដឹង អ្នកដទៃ។ កំណែទំរង់ នេះ ត្រូវតែ ជា គូ នឹង កំណែទំរង់ នៃ ការអប់រំ ហើយ នឹង កំណែទំរង់ នៃ ជីវិត ដែល ត្រូវតែ ជា គូ ជាមួយ នឹង កំណែ ទំរង់ ផ្សេងៗ ទៀត។

ក្រមសីលធម៌ ប្រជាពលរដ្ឋ

គឺ ជា សីលធម៌ របស់ ពលរដ្ឋ ម្នាក់ៗ រស់នៅ មាន សិទ្ធិ តែ ក៏ ត្រូវ ទទួលបន្ទុក ករណីយកិច្ច ជា ពលរដ្ឋ សំរាប់ សមូហភាព។ សិទ្ធិ និង ករណីយកិច្ច នេះឯង បង្កើត ការយល់ដឹង អ្នកដទៃ និង ស្គាល់ ខ្លួនឯង ក្នុង ការរស់នៅ នៅក្នុង ប្រជាជាតិ ដែល ជា ទម្រង់ មួយ នៃ សមូហភាព តម្រូវ ឱ្យមាន បរទត្តភាព, មិត្តភាព និង សេចក្តីស្នេហា។ ឥទ្ធានុភាព នៃ ពលរដ្ឋ ម្នាក់ៗ វា អាច ធ្វើ អោយ ប្រជាជាតិ រុងរឿង បាន, ដូច្នេះ ពលរដ្ឋ ម្នាក់ៗ ត្រូវ មាន អត្តសញ្ញាណ រឹងមាំ ហើយ រួមរស់ នៅ ក្នុង សមូហភាព ប្រកប ទៅ ដោយ លទ្ធភាព អាច មាន ទំនាក់ទំនង ដោយ រលូន ជាមួយនឹង អ្នកដទៃ។ ដ្បិត តម្លៃ របស់ បុគ្គល នីមួយៗ វា

ជា ថាមពល, តម្លៃ របស់ សមូហភាព វា បង្កើត ថាមពល រួម, ហើយ តម្លៃ ទាំង ពីរ រួម គ្នា នេះឯង ដែល បង្កើត គុណភាព ល្អ សំរាប់ ប្រជាជាតិ។

ក្រមសីលធម៌ នៃ ជាតិមនុស្ស

ដូចជា ក្រមសីលធម៌ សកល ដែរ ដែល ពាក់ព័ន្ធ នឹង មនុស្ស លោក វា ហាក់ដូចជា អ្ករូបី មុន នឹង ចាប់ផ្តើម មាន សម័យ ផែនដី ដែល មាន សហគមន៍ នៃ ជោគវាសនា រួម របស់ មនុស្ស លោក។ អត្តភាព សហគមន៍ នេះ នាំ ឱ្យ មាន ភាពពិត នៃ មនុស្សជាតិ សំរាប់ មនុស្សលោក។ ដូច្នេះ មនុស្ស ម្នាក់ៗ អាច ប្រព្រឹត្ត អ្វី មួយ ដើម្បី មនុស្សជាតិ គឺថា រួមចំណែក ជា បឋម ក្នុង ការយល់ដឹង អំពី សហគមន៍ នៃ ជោគវាសនា រួម ហើយ ទុក ខ្លួន ដោយ ខ្លួនឯង ជា ពលរដ្ឋ របស់ ពិភពលោក មាតុភូមិ ដែល ខ្លួន ជា សមាជិក ពេញលេញ ក្នុង ឋាន: ខ្លួន ជា ជាតិមនុស្ស។

សេចក្តីសន្និដ្ឋាន

សម្តេច Dalaï Lama ព្រះអង្គ មាន ព្រះបន្ទូល ថា ចេតភាព (spiritualité) ដំបូង របស់ យើង គឺ វា សំខាន់ ជាង សាសនា ទៅ

ទៀត[6]។ គំនិត នេះ វា ជា ទំនោរចិត្ត ដែល មនុស្សលោក មាន នៅក្នុង ចិត្ត ថា ដើម្បី សេចក្តីស្រឡាញ់, សេចក្តីសប្បុរស និង មិត្តភាព វា ជា ចិត្ត ឯករាជ ពី ជំនឿ សាសនា ដែល យើង ប្រកាន់ខ្ជាប់។ ចំពោះ ព្រះអង្គ ទ្រង់ មាន ជំនឿស៊ប់ ថា មនុស្ស លោក អាច មិន ជឿ សាសនា តែ មិន អាច មិន ជឿ លើ តម្លៃ នៃ មនុស្ស បាន នោះឡើយ។ ជា ឧទាហរណ៍ គឺ ភាពមិនដូចគ្នា រវាង តែ និង ទឹក។ ក្រមសីលធម៌ និង តម្លៃ នៃ មនុស្ស នៅក្នុង បរិបទ សាសនា វា ដូចគ្នា នឹង តែ។ តែ ដែល យើង ពិសា វា ផ្សំ ភាគច្រើន ដោយ ទឹក និង ក្រឿងផ្សំ ជា ច្រើន ទៀត ដូចយ៉ាង ស្លឹកតែ, ក្រឿងទេស, ជួន មាន ដាក់ ស្ករ - នៅ ប្រទេស ទីបេ មាន ថែម ក្រឿង ហ៊ីរ និង អំបិល បន្តិច - ការផ្សំ នេះ ឯង ដែល ធ្វើ អោយ ទឹកតែ មាន រស់ជាតិ ឆ្ងាញ់ ដែល យើង ចង់ ពិសា តែ មនុស្សយើង អាច មិន ពិសា ទឹកតែ បាន តែ មិន អាច រស់ ឥត ទឹក បាន ឡើយ។ ដូចគ្នា មនុស្ស អាច ឥត សាសនា តែ ត្រូវការ ជា សំខាន់ គឺ សេចក្តីអាសូរ ចំពោះ អ្នកដទៃ។ យើង យើញ ថា សុខុមាលភាព នៃ ចេតភាព មិន អាស្រ័យ លើ សាសនា, តែ អាស្រ័យ លើ ធម្មជាតិ មាន ពី កំណើតមក ដូច យ៉ាង សម្បទា ចំពោះ សេចក្តីសប្បុរស, សេចក្តីអាសូរ និង ការ ក្រៀមបង្ហារ ដើម្បី ការពារ អ្នកដទៃ។ ធម្មជាតិ ដែល មាន ពី

[6] L'appel au Monde du Dalaï Lama – entretien avec Franz Alt – Edition BEN EVE NTO.

កំណើត នេះឯង ដែល ជា ក្រមសីធម៌ សំខាន់ និង ជាតិមនុស្ស ដែល មាន នៅក្នុង ធាតុ នៃ មនុស្សលោក។

ដូច្នេះ យើង អាច សន្និដ្ឋាន បាន ថា កំណែទំរង់ សីលធម៌ ក៏ អាច និយាយ បាន ថា វា ជា មាគ៌ា នៃ អនាគត នៃ មនុស្ស ជាតិ តែ ក៏ អាច យល់ ផង ដែរ ថា វា ជា និយតកម្ម ធម្មតា នៃ ការវិវត្តន៍ នៃ មហាយាត្រា នៃ មនុស្សជាតិ។ អ្វី ដែល ជា អកុសល សំរាប់ ជាតិមនុស្ស វា ត្រាន់ តែ ជា ត្រោះថ្នាក់ ដែល មនុស្សជាតិ ជួបប្រទះ។ តែ ត្រូវដឹង ថា មនុស្សជាតិ មាន កម្លាំង កុសល ត្រប់ត្រាន់ សំរាប់ លុបបំបាត់ ត្រប់ អកុសល ដែល មាន កើតឡើង ពិត តែ វា កាត់តែ មាន តិចឡើងៗ នៅ ក្នុង ការវិវត្តន៍ របស់ ខ្លួន។